**សំណួរ**

**អ្វីទៅជាទង្វើរើសអើង បំពានសិទ្ធិមនុស្ស (non-discrimination)?**

**ចម្លើយ**

នៅក្នុងពិភពលោកយើងនេះ ជាសត្យានុម័ត វាតែងតែមាននូវភាពខុសគ្នា និងការប្រព្រឹត្តខុសគ្នា ទៅលើមនុស្សឬក្រុមមនុស្ស។ ការតម្រូវឲ្យមានការប្រព្រឹត្តដូចគ្នា ឬស្មើគ្នាពិតជាមិនអាចទៅរួចទេ។ ក្នុងន័យនេះ ការហាមឃាត់ទង្វើរើសអើង ទំនងជាមានន័យជាក់លាក់ណាមួយ។ តើអ្វីទៅជាទង្វើរើសអើង?

ទង្វើរើសអើង ជាទង្វើប្រព្រឹត្តខុសគ្នា ធ្វើឲ្យប៉ះដល់សិទ្ធិ និងផ្អែកលើមូលដ្ឋាន ដូចជា ភេទជាដើម។[1] យុត្តិសាស្ត្របាន កំណត់នូវធាតុផ្សំចំនួន ២៖ ១. ការប្រព្រឹត្តខុសគ្នា និង ២. ការប្រព្រឹត្តខុសនេះ មិនសមហេតុផល (unreasonable)។ ឧទាហរណ៍ ការបដិសេធ មិនផ្តល់ការងារជូន ជនជាតិស្បែកខ្មៅ គ្មានហេតុផលអ្វីក្រៅពីថា ពួកគេមានស្បែកខ្មៅ។ នេះជាអំពើរើសអើង។

កតិកាសញ្ញា ស្តីពីសិទ្ធិស៊ីវិល និងនយោបាយឆ្នាំ ១៩៦៧ មាត្រា ៦ ចែងហាមប្រហារជីវិតកុមារទំនាស់នឹងច្បាប់ ហើយ មាត្រា ៤៤ នៃ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ កម្ពុជា ចែងផ្តល់សិទ្ធិកម្មសិទ្ធិលើដី (right to own land) សម្រាប់តែប្រជាជនមានសញ្ជាតិកម្ពុជា បង្ហាញនូវហេតុផលសមស្រប។ ក្នុងករណីចុងក្រោយ ប្រសិនបើអនុញ្ញាតឲ្យជនបរទេសណា ក៏អាចកាន់កាប់ដីបាន វាទំនងជាគ្រោះថ្នាក់ និងប៉ះពាល់ដល់អធិបតេយ្យភាពនៃកម្ពុជា។ នេះជាហេតុផលសមស្រប ហើយជាទូទៅ ច្បាប់ភូមិបាលនៃប្រទេសដទៃក៏កំណត់ដូចនេះដែរ។ ដូចនេះ វាមិនមែនជាច្បាប់រើសអើងទេ។ ក្រមព្រហ្មទណ្ឌ ២០០៩ ចែងក្នុងផ្នែកមួយមានមាត្រា២៦៥ (បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬសេវា) ដល់ មាត្រា ២៧៣ ចាត់ជាបទល្មើស ជាមួយនិងទោសទណ្ឌ សម្រាប់អំពើរើសអើង។

Further readings: Human Rights Committee (HRC), *CCPR General Comment No. 18: Non-discrimination*, 10 November 1989, available at: https://www.refworld.org/docid/453883fa8.html [accessed 13 September 2019]; David Simon, Discrimination and Affirmative Action, https://www.kon.org/urc/simon.pdf; European Court of Human Rights, *Case of James and Others v. the United Kingdom*, No. 8793/79, 21 February 1986, para.63.

---

[1] UN General Assembly, *Convention on the Elimination of All Forms of Discrimination Against Women*, 18 December 1979, United Nations, Treaty Series, vol. 1249, p. 13, available at: https://www.refworld .org /do cid/ 3ae6b3970 .html [accessed 13 September 2019]